**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបោះពុម្ពអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល

ក្រសួងមុខងារសាធារណៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់មន្ត្រីរាជការស៊ីវិលបម្រើការងារនៅតាមក្រសួង ស្ថាប័ន នៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសាធារណជន មេត្តាជ្រាបថា ដោយបានទទួលគោលការណ៍ឯកភាពដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងមុខងារសាធារណៈ នឹងរៀបចំបោះពុម្ពឡើងវិញនូវអត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួនរបស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់ការប្រើប្រាស់ជាផ្លូវការ។

កន្លងមក អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការ ត្រូវបានបោះពុម្ព និងផ្តល់ជូនមន្ត្រីរាជការស៊ីវិលប្រើប្រាស់ជាផ្លូវការមកដល់ឆ្នាំ ២០១៥ ប៉ុន្តែត្រូវបានអាក់ខានរហូតមកដល់សព្វថ្ងៃ។

សម្រាប់ការរៀបចំបោះពុម្ពឡើងវិញនេះ ដោយផ្អែកលើការវិវត្តជឿនលឿននៃបច្ចេកវិទ្យា ស្របតាមប្រក្រតីភាពថ្មីនៃបរិបទកូវីដ-១៩ ក្រសួងមុខងារសាធារណៈ បានរៀបចំបោះពុម្ព និងផ្តល់ជូននូវអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិលក្នុងទម្រង់ថ្មី ជាប្រភេទ "**ស្មាតកាត**" (Smart Card) ដែលអាចអនុញ្ញាតឱ្យមន្ត្រីរាជការប្រើប្រាស់ជាប័ណ្ណសម្គាល់ខ្លួនផង ជាប័ណ្ណអេធីអឹម (ATM) សម្រាប់ដកប្រាក់បៀវត្សពីធនាគារផង និងអាចប្រើប្រាស់ជាមធ្យោបាយសម្រាប់មុខងារចាំបាច់ដទៃទៀត។

ទន្ទឹមនោះ ដោយមានការសម្របសម្រួលនិងការគាំទ្រពីដៃគូសហការរបស់រដ្ឋ ចំណាយលើការបោះពុម្ពអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិលប្រភេទថ្មីនេះ ត្រូវបានរ៉ាប់រងដោយធនាគារឯកជន ហើយពុំតម្រូវឱ្យម្ចាស់ប័ណ្ណបង់ថ្លៃឡើយ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមមន្ត្រីរាជការស៊ីវិលនិងសាធារណជននៅទូទាំងព្រះរាជាណាចក្រកម្ពុជាមេត្តាជ្រាប និងចូលរួមសហការឱ្យបានល្អប្រសើរ។

ថ្ងៃអង្គារ ៤កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០២២

# អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការស៊ីវិល

(គំរូថ្មី)

ផ្ទៃខាងមុខ




ផ្ទៃខាងក្រោយ




ផ្ទៃខាងមុខ




ផ្ទៃខាងក្រោយ




ផ្ទៃខាងមុខ




ផ្ទៃខាងក្រោយ

